# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ២០១៣

## ជប៉ុនផ្តល់៧៨,៤៣០ដុល្លារអាមេរិកសម្រាប់គម្រោងសាងសង់ផ្ទះកុមារ



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណៃ) រដ្ឋាភិបាលជប៉ុនបានផ្តល់ទឹកប្រាក់សរុបចំនួន ៧៨,៤៣០ ដុល្លាអាមេរិក ដល់សាលាសង្កាត់គោករកា ខណ្ឌ ពោធិ៍សែនជ័យ រាជធានីភ្នំពេញសម្រាប់គម្រោងសាងសង់ផ្ទះកុមារ និងមណ្ឌលសហគមន៍ក្នុងសង្កាត់គោករកា រាជធានីភ្នំពេញ។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយលោក ហ៊ីហ្គូជិ យ៉ូស៊ីហ៊ីរ៉ូ ភារៈធារីស្តីទីស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងលោក ភី ណុប ប្រធានក្រុមប្រឹក្សាសង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញនៅស្ថានទូតជប៉ុន។



ដើម្បីកែលម្អបរិស្ថានផ្ទះកុមារ សាលា សង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ រាជ ធានីភ្នំពេញនឹងអនុវត្តគម្រោងសាងសង់អគារថ្មកម្ពស់ពីរជាន់មួយខ្នងដោយមានបំពាក់គ្រឿងសង្ហារឹមផងនៅក្នុងភូមិអណ្តូង សង្កាត់គោករកា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ជាផ្នែកមួយក្នុងគម្រោងនេះដែរ បង្គន់អនាម័យ និងផ្ទះបាយក៏នឹងត្រូវបានសាងសង់ផងដែរ។ ផ្ទះកុមារថ្មីនេះក៏នឹងក្លាយទៅជាមណ្ឌលសហគមន៍ដែលអាចឲ្យអ្នកម្តាយទាំងឡាយដែលនៅក្នុងសហគមន៍អាចចែករំលែកចំណេះដឹងក្នុងការបីបាច់កូន និង វិធីសាស្រ្តកែលម្អជីវភាពរស់នៅរបស់ពួកគេផងដែរ។ យើងរំពឹងថា ក្មេងៗជាង៦០នាក់ និងម្តាយរបស់ពួកគេនឹងអាចប្រើប្រាស់បរិក្ខារដែលត្រូវបានកែលម្អនេះ។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណៃ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និង ស្តាបនាប្រទេសឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង ភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការ ចិញ្ចឹមជិវិត និង សេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជា ជួយជុំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកា ជាង ៤៨.៨ លានដុល្លាអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៨៧ គម្រោង នៅទូទាំង ប្រទេស។



---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល:* *eco.jpn@.pp.mofa.go.jp*
*គេហទំព័រ:* *http://www.kh.emb-japan.go.jp*